ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២២

នៅក្នុងខែមករានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម តាមបែបគន្លងប្រក្រតីភាពថ្មី លើវិស័យនៃការងារសំខាន់ៗជាច្រើន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនដោយទទួលបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងបើកសម័យប្រជុំលើកទី៨ព្រឹទ្ធសភាចំនួន០១លើក ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់៖

-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម

-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ

២-ស្តាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៧ និងលើកទី៨ នីតិកាលទី៤

៣-ការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤ ជំនួសលោកជំទាវ **ឱ សុខុម** ដែលបានទទួលមរណភាព

៤-ការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រឹទ្ធសភា នីតិកាលទី៤

៥-ពិនិត្យ និងសម្រេចលើសំណើរបស់គណបក្សប្រជាជនកម្ពុជាលេខ:០៤៤/១២២១/



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oumsarith_sgsenate@gmail.com, oumsarith_sgsenate@yahoo.com

លគ.គក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា ប្រជុំបើកទូលាយជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់ ពីរាជរដ្ឋាភិបាល និងរដ្ឋសភា

-បានផលិតឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចចំនួន០៩លើក។

**២- មុខងារតាមដានការអនុវត្តច្បាប់**

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ស្តីពី វឌ្ឍនភាព និងឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមក្នុងពិធីជួបសវនាការការងារជាមួយ ឯកឧត្តម **ប៉ែន កុសល្យ** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ដើម្បីឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស និងការអនុវត្តច្បាប់ តាមដាន និងជំរុញការដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ សិទ្ធិដីធ្លី និងសិទ្ធិទទួលបានសុខភាព ជាពិសេសស្ត្រី និងកុមារក្នុងអំឡុងពេលមានវិបត្តិកូវីដ-១៩ ព្រមទាំងស្តាប់ការបំភ្លឺអំពីការដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋចំនួន៦៥៤គ្រួសារ ទាក់ទងនឹងករណីដីធ្លី នៅសង្កាត់សំរោង ក្រុងសំរោង និងឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។

**៣- មុខងារតំណាង**

- បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី កងកម្លាំង អាជ្ញាធរសង្កាត់ និងចុះសួរសុខទុក្ខឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា ដែលកំពុងសម្រាកព្យាបាលជំងឺនៅរាជធានីភ្នំពេញ, ប្រារព្ធពិធីបង្សុកូល ឧទ្ទិសកុសលជូនដល់មាតា បិតា បុព្វការីជន ញាតិកាទាំង៧សន្តាន និងពិនិត្យសមិទ្ធផលក្នុងវត្តសុវណ្ណគីរី នៅខេត្តកំពង់ចាម ព្រមទាំងអញ្ជើញចូលរួមពិធីគោរពវិញ្ញាណក្ខន្ធ និងទស្សនាទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាសមិទ្ធផលថ្មី ជាប្រវត្តិសាស្ត្រ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ដើម្បីជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ អាជ្ញាធរគ្រប់

លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍហេដ្ឋា-រចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល អប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយជំងឺកូវីដ-១៩ ព្រមទាំងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាកចំនួន៩៩លើក នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តកោះកុង ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តព្រៃវែង និងខេត្តស្វាយរៀង

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរសង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកតាសេក និងសង្កាត់ព្រែកលៀប ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងជាអធិបតីក្នុងពិធីបុណ្យសព ឯកឧត្តមបណ្ឌិត **ឃឹម ឈុនអ៊ី** ទីប្រឹក្សាច្បាប់អមរដ្ឋសភា និងជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់នៃរដ្ឋសភា នៅវត្តបទុមវតី រាជធានីភ្នំពេញ

- ឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរសង្កាត់បាក់ខែង និងសង្កាត់កោះដាច់ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- បានផ្តល់សេវាជូនក្រុមការងាររបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា** អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកំពង់ឆ្នាំង

- បានទទួលពាក្យបណ្តឹងចំនួន១០ករណី កំពុងពិនិត្យសិក្សាចំនួន១៤ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៣ករណី និងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន០១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន០៣ករណី

- បានផ្ញើលិខិតអបអរសាទររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសដែលសម្តេចត្រូវបានជ្រើសរើសជាជ័យលាភី **ពានរង្វាន់សន្តិភាពស៊ុនហាក់ ឆ្នាំ២០២២** (SUNHAK PEACE PRIZE 2022) ពីមូលនិធិសន្តិភាពស៊ុនហាក់របស់សាធារណរដ្ឋកូរ៉េ

- បានចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូន**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងឱកាសចម្រើនជន្មាយុ

- បានផ្ញើសាររំលែកទុក្ខជូនគ្រួសារសពមន្ត្រីជាន់ខ្ពស់ចំនួន០៣លើក

- បានផលិតទស្សនាវដ្តីប្រចាំខែមករា ឆ្នាំ២០២២ ចំនួន៨០០ក្បាល។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម ជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយឯកឧត្តម BUI THANH SON រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងលោក **អាស្សាអាត អាល់ហ្សាវ៉ារី** ប្រតិភូតំណាងអង្គការបណ្តុះបណ្តាលវប្បធម៌ឥស្លាមកូវ៉ែត ដែលជាប្រភពម្ចាស់ជំនួយរបស់សមាគមប្រភពល្អកម្ពុជា ព្រមទាំងឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាទើបតែងតាំងថ្មី ប្រចាំប្រទេសនានាចំនួន០៣រូប រួមមានឯកឧត្តម **ទុយ រី** ឯកអគ្គរាជទូតប្រចាំព្រះរាជាណាចក្រជប៉ុន ឯកឧត្តម **កែវ ឈា** ឯកអគ្គរាជទូតប្រចាំសហរដ្ឋអាមេរិក និងម៉ិកស៊ិកូ និងឯកឧត្តម **ផន ពៅ** ឯកអគ្គរាជទូតប្រចាំសាធារណរដ្ឋហ្វីលីពីន

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងពិភាក្សាការងារជូនសមាជិកព្រឹទ្ធសភា ជាមួយឯកអគ្គរដ្ឋទូតសាធារណរដ្ឋសិង្ហបុរី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា, ក្រុមអ្នកវិនិយោគទុនមកពីព្រះរាជាណាចក្រជប៉ុន និងប្រតិភូក្រុមប្រឹក្សាភិបាលសាលាអន្តរជាតិប៉ារ៉ាហ្គោន (Paragon International School)

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យអគ្គទីប្រឹក្សានៃស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបពិភាក្សាការងារ

- បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU)ស្តីពី កិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាមួយរាជបណ្ឌិត្យសភាកម្ពុជា

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតបារាំង, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ដៃគូភាគីចិន, ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការមូលនិធិអាស៊ី, មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ(HRD), មជ្ឈមណ្ឌលសភាអាស៊ី(PCA), វិទ្យាស្ថានSalaCyber, វិទ្យាស្ថានDataU Academy, វិទ្យាស្ថានCamKPI Professional Academy, វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(NIPTICT), ភ្នាក់ងារសង្គមព័ត៌មានជាតិ(NIA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, ក្រុមហ៊ុនCambodia Hosting និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាលជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- បានសហការ និងសម្របសម្រួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី៤(ដូសជំរុញ) ជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា, ថ្នាក់ដឹកនាំ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ, មន្ត្រីរាជការ និង បុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំពិនិត្យផែនការមេស្តីពី បរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិច (ឆ្នាំ២០២២-២០៣០)

- បានប្រជុំការងារបុគ្គលិកនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំជាមួយមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលបានបញ្ចប់ការសិក្សា ថ្នាក់បណ្ឌិតក្នុង និងក្រៅប្រទេស

- បានរៀបចំកម្មវិធីបទបង្ហាញស្តីពី ការចែករំលែកវិធីសាស្ត្រក្នុងការស្នើសុំការគាំទ្រពីមិត្តចិន

- បានរៀបចំកម្មវិធីបទបង្ហាញរបស់បេឡាជាតិសន្តិសុខសង្គម(ប.ស.ស )

- បានរៀបចំធ្វើបាឋកថាជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាស្តីពី អ្នកដឹកនាំគឺ ជាអ្នកបំរើ

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្រប នឹងដំណាក់កាលថ្មីៗ

### ៥.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖

- បានទទួលលិខិតចូលចំនួន១,០៩០ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣០៤ច្បាប់

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បានបើកប្រាក់បៀវត្សប្រចាំខែមករា ឆ្នាំ២០២២ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក ព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំ ខែមករា ឆ្នាំ២០២២

- បានរៀបចំតារាងប្រាក់បៀវត្សប្រចាំឆ្នាំ២០២២ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានរៀបចំរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភាឆ្នាំ២០២១ និងការបែងចែក និងប្រើប្រាស់ ថវិកាព្រឹទ្ធសភាឆ្នាំ២០២២ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន២៤ច្បាប់ និងធ្វើប័ណ្ណសម្គាល់ខ្លួនចំនួន ២០ប័ណ្ណ

- បានបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេសចំនួន០៤វគ្គ មានសិក្ខាកាមចូលរួមចំនួន ៤៦នាក់

- បានផ្សព្វផ្សាយអាហារូបករណ៍ថ្នាក់បណ្ឌិត អនុបណ្ឌិត និងថ្នាក់បរិញ្ញាបត្រ សម្រាប់ឆ្នាំសិក្សា២០២២ ជូនដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានរៀបចំផ្ទេរខុទ្ទកាល័យអគ្គលេខាធិការរង អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈទៅកាន់ទីតាំងថ្មី

- បានរៀបចំបន្ទប់គ្រូពេទ្យ និងបំពាក់សម្ភារ បរិក្ខារសម្រាប់ថែទាំសុខភាពជូនសមាជិកព្រឹទ្ធសភា

- បានពង្រីកផ្នែកខាងក្រោយសាលបណ្ណាល័យព្រឹទ្ធសភា

- បានជួសជុលកែលម្អស្លាបខាងកើត និងខាងលិចផ្នែកខាងក្រោមអគារក្រហម, អគារខុទ្ទកាល័យ, អគារអគ្គលេខាធិការរងចាស់ និងអគារអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ និងផ្កានានាចំនួន០៨ប្លង់ ព្រមទាំងបានចាត់កម្លាំងកាប់មែកឈើ ដាំដើមឈើ និងផ្កា នៅខាងមុខអគារនានាចំនួន០៥លើក

- បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក ត្រួតពិនិត្យជណ្តើរយន្ត ត្រួតពិនិត្យសត្វកណ្តៀរ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២២៧គ្រឿង/លើក

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែមករា ឆ្នាំ២០២២ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

**៥.២-ការងារសេវាច្បាប់ ៖**

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន២៥២ច្បាប់

- បានធ្វើកំណត់បង្ហាញព្រះរាជក្រម អនុក្រឹត្យ សេចក្តីសម្រេច សារាចរណែនាំ របាយ-

ការណ៍សវនកម្ម សេចក្តីជូនដំណឹង និងលិខិតផ្សេងៗចំនួន៥៨ច្បាប់

- បានធ្វើប្រតិទិនសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០២១-២០២៤)

- បានចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ។

*៥.៣-ការងារស្រាវជ្រាវ៖*

- បានតាមដានការកាត់បន្ថយចំណាយរបស់រាជរដ្ឋាភិបាល និងសិក្សាស្រាវជ្រាវ ចងក្រងការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន២៨អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែមករា ឆ្នាំ២០២២ ចំនួន០២ច្បាប់។

***៥.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖***

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលម៉ាស៊ីនកុំព្យូទ័រ Laptop Ipad Smart Phone និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន១០៩គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន៧៨ប្រធានបទ

- បានបន្តចាត់ចែងការផលិតខ្សែវីដេអូអំពីប្រវត្តិអគារព្រឹទ្ធសភាក្នុងបរិវេណវិមានរដ្ឋចំការមន

- បានផលិតវីដេអូសមិទ្ធផលស្តីពី វឌ្ឍនភាពការងាររយៈពេល២ឆ្នាំ របស់គណៈកម្មការទី២ព្រឹទ្ធសភា (ឆ្នាំ២០២០-២០២១)

- បានទទួល និងរៀបចំសៀវភៅច្បាប់ ឯកសារ និងសៀវភៅតាមជំនាញផ្សេងៗចំនួន២២២ក្បាល ព្រមទាំងទស្សនាវដ្តីចំនួន១០ច្បាប់

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៥៧លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២៥លើក

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Chanel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន ១,៧១៥ប្រធានបទ

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃ

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្ដាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន។

**៥.៥-ការងារពិធីការ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៥លើក

- បានតាមដាន និងចងក្រងសេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១២ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែមករា ឆ្នាំ២០២២ ចំនួន០១ច្បាប់

- បានកសាងជំនួយស្មារតី ធ្វើលិខិតអបអរសាទរ និងលិខិតថ្លែងអំណរគុណ ព្រមទាំងបកប្រែឯកសារនានា ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន៥៣លើក។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

- បានពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៣៩ច្បាប់

- បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព និងធ្វើហ្វុងអក្សរចំនួន១៣លើក

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៥ច្បាប់ ស្មើនឹង១១៩នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៣ច្បាប់ ស្មើនឹង០៣នាក់

- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន១៣៨លើក

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥៦សំណើ

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២៦លើក មានអ្នកចូលរួមចំនួន១,១៩០នាក់

- បានសួរសុខទុក្ខមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបគ្រោះថ្នាក់ចរាចរណ៍

ចំនួន០១នាក់

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២៤០លីត្រ តាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន៥,១៩៦ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន៤១៩ក្បាល អស់ក្រដាសចំនួន៦៦,២៨៧សន្លឹក

- បានផ្ដល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុង ចំនួន១៥៨លើក ស្មើនឹង២៨៣នាក់។ បានជួសជុល ប្ដូរប្រេងម៉ាស៊ីន និងអាគុយរថយន្តចំនួន ០៨គ្រឿង

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន០៧លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្ដីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន៣៥២លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន២៥លើក។

**III-ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២២**

***-បន្តអនុវត្តវិធានការ "៣ការពារ ៣កុំ" ពាក់ម៉ាស់ ធ្វើតេស្តពេលចាំបាច់ និងវិធានការចាំបាច់ផ្សេងៗទៀត (ដាក់ឱ្យនៅដាច់ដោយឡែក រឹតត្បិតឡុកដោន) ប្រឆាំងនឹងជំងឺកូវីដ-១៩ និងបន្តយកចិត្តទុកដាក់ធ្វើការងារមនុស្សធម៌ក្នុង និងក្រៅស្ថាប័នឱ្យបានទាន់ពេលវេលា៖***

+យកចិត្តទុកដាក់តាមដានសុខភាពរបស់សមាជិកព្រឹទ្ធសភា

+យកចិត្តទុកដាក់តាមដានសុខភាព លក្ខខណ្ឌការងារ និងជីវភាពទូទៅក្នុងក្របខណ្ឌស្ថាប័នទាំងមូល

+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ-១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន

+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្ដាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេក-

វិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

**-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារៗ វត្តមានមន្ត្រី បុគ្គលិកវិលមកប្រក្រតីភាពវិញគឺ១០០%ដើម្បីៈ**

+ធានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងបើកសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ អញ្ជើញចូលរួមពិធីបុណ្យជាតិសំខាន់ៗ

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ អាជ្ញាធរដែនដី និងចុះចែកអំណោយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងកម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃបរិបទកូវីដ-១៩

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស មជ្ឈមណ្ឌលសភាអាស៊ី(PCA) និង

វិទ្យាស្ថានចក្ខុវិស័យអាស៊ី។ ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ឡើងវិញជាមួយដៃគូសំខាន់ៗរបស់មជ្ឈមណ្ឌលសភាអាស៊ី(PCA) ជាមួយរដ្ឋសភា-ព្រឹទ្ធសភាបារាំង លេខាធិការដ្ឋាន(APF) លេខាធិការដ្ឋាន(AIPA) និង(KPI) ព្រមទាំងដៃគូថ្មីមួយចំនួនទៀត (វិទ្យាស្ថានសភាឡាវ)

-ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCA) តាមការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលជាបន្តបន្ទាប់

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ (PCA, ITECH, MFE, APF) និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងការចូលរួមមហាសន្និបាត និងវេទិកានានាក្នុងក្របខណ្ឌ (IPU, APF, AIPA...)។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ត្រៀមរៀបចំបែបបទស្នើសុំជំនួយពីរាជរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ

-ត្រៀមចាប់ផ្តើមកសាងអគារថ្មី១ខ្នង

-បញ្ចប់ការជួសជុល កែលម្អអគារអតីតនាយកដ្ឋានព័ត៌មានវិទ្យា(ICT) ក្រោមអគារក្រហម និងការពង្រីកអគារបណ្ណាល័យ

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែកុម្ភៈ ឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា

-យកចិត្តទុកដាក់អនុវត្តគោលការណ៍ 3E's ដោយផ្តោតលើការងារជាអាទិភាព សំខាន់ចាំបាច់ និងបន្ទាន់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ធ្វើតបញ្ចូលការប្រើប្រាស់គ្រឿងយន្តអគ្គិសនី និងពង្រីកការបំភ្លឺដោយថាមពលព្រះអាទិត្យ

ដើម្បីថែរក្សាធម្មជាតិបៃតង កាត់បន្ថយចំណាយ និងការប្រើកម្លាំងមនុស្ស ហើយចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-អនុវត្តការងារដើមឆ្នាំ តាមបរិបទកូវីដ-១៩ ដោយសម្រេចឱ្យបាននូវការងារជាអាទិភាពលើកផែនការ និងកម្មវិធីការងាររបស់ស្ថាប័ន និងគ្រប់អង្គភាពឆ្នាំ២០២២

-ធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស តម្រូវការ និងការប្រឈម

-ត្រៀមរៀបចំចងក្រងសៀវភៅបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំថ្មី

-គិតគូររៀបចំដំឡើងតាមឋានន្តរសក្តិ និងថ្នាក់ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់ឆ្នាំ២០២១-២០២២

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តបម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ការអនុវត្តផែនការបណ្តុះបណ្តាលធនធានមនុស្សតាមកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា

-ការប្រជុំពីចម្ងាយ ការធ្វើការពីចម្ងាយ និងការរៀនសូត្រពីចម្ងាយ គឺជាឧបករណ៍ថ្មីវិធីសាស្ត្រថ្មីក្នុងបរិបទកូវីដ-១៩ ហើយអាចនៅបន្តក្រោយជំងឺកូវីដ-១៩

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងការគ្រប់គ្រងការប្រើប្រាស់ Internet

-ទំនាក់ទំនង និងជំរុញសុំការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតចិនគម្រោងជំនួយក្នុងការសាងសង់អគារសាលប្រជុំពេញអង្គថ្មី និងបំពាក់សម្ភារមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានវិទ្យា(ICT)

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានាៗលៗ)

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-បន្តការផលិតខ្សែវីដេអូអំពីប្រវត្តិអគារព្រឹទ្ធសភាក្នុងបរិវេណវិមានរដ្ឋចំការមនៗ

## IV-សេចក្តីសន្និដ្ឋាន

ក្នុងខែមករានេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់គ្រប់ការដ្ឋាន ដើម្បីបញ្ចប់ការងារដែលនៅសេសសល់ពីឆ្នាំ២០២១ ហើយជាជំហានដំបូងដើមឆ្នាំសម្រាប់អនុវត្តផែនការប្រតិបត្តិឆ្នាំ២០២២ តាមក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភា ព្រមទាំងចូលទំព័រថ្មីនៃដំណើរការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅតែបន្តការងារជាអាទិភាពលើមុខងារស្នូលទាំង៣របស់ខ្លួន ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងបើកសម័យប្រជុំលើកទី៨ព្រឹទ្ធសភា នីតិកាលទី៤ បានដោយរលូន។ ដោយឡែកមុខងារតំណាងបានអមដំណើរសមាជិកព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធ ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេសអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយជំងឺកូវីដ-១៩ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋ ដែលកំពុងជួបការលំបាក ព្រមទាំងប្រជាពលរដ្ឋរងគ្រោះមហន្តរាយផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយគណៈប្រតិភូអន្តរជាតិ ព្រមទាំងកិច្ចប្រជុំនានាប្រព្រឹត្តទៅដោយរលូន។

មន្ត្រីរាជការទាំងអស់ បានទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី៤(ដូសជំរុញ) និងត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២២

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ